# ជ័យជោគនៃជនជាប់ចោទ និងការរង់ចាំយុត្តិធម៌ចុងក្រោយរបស់ជនរងគ្រោះ

ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៥

**លីម ជ័យវ័ត្ត**
**អ្នកសង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម**
**មជ្ឈមណ្ឌលឯកសារកម្ពុជា**

នៅពេលបច្ចុប្បន្ន ទោះបីជាអង្គជំនុំជម្រះសាលាដំបូងនៃសាលាក្តីខ្មែរក្រហមបានចេញសាលក្រមដាក់ទោសជនជាប់ចោទ នួន ជា និង ខៀវ សំផន ដាក់ពន្ធនាគារអស់មួយជីវិតនៅក្នុងសំណុំរឿង០០២ ដំណាក់កាលទី១ (ឬហៅម្យ៉ាងទៀតថា សំណុំរឿង០០២/០១) កាលពីថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ហើយក៏ដោយ ជនជាប់ចោទទាំងពីររូបនៅតែត្រូវបានសន្មតថាជាជនដែលគ្មានទោសនៅឡើយ ដរាបណាពុំទាន់មានសាលដីកាស្ថាពរពីអង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៥ខាងមុខ អង្គជំនុំជម្រះតុលាការកំពូលនឹងបើកសវនាការលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា បណ្តឹងសាទុក្ខរបស់ជនជាប់ចោទ នួន ជា និង ខៀវ សំផន ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០២/០១ ។ យោងតាមការព្យាករណ៍របស់អង្គជំនុំជម្រះ ដើម្បីចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍នេះ អង្គជំនុំជម្រះតុលាការកំពូលអាចនឹងចំណាយពេលយ៉ាងហោចណាស់១៨ខែ ។[១] ពោលគឺ គេត្រូវរង់ចាំរហូតដល់ត្រីមាសទី១ក្នុងឆ្នាំ២០១៦ ទើបមានសាលដីកាស្ថាពរ ដើម្បីកំណត់ថា តើជនជាប់ចោទ នួន ជា និង ខៀវ សំផន ពិតជាមានពិរុទ្ធភាពដូចការចោទប្រកាន់របស់សហព្រះរាជអាជ្ញាមែនឬយ៉ាងណា...បញ្ហាសុខភាព ភាពទ្រុឌទ្រោមផ្នែករាងកាយ និងវ័យកាន់តែចាស់ជរារបស់ជនជាប់ចោទទាំងពីររូប បានក្លាយជាក្តីបារម្ភរបស់ភាគីពាក់ព័ន្ធ អំពីលទ្ធភាពដែលថាជនជាប់ចោទអាចនឹងស្លាប់មុនពេលមានសាលដីកាស្ថាពរ ។ ឧទាហរណ៍ជាក់ស្តែងចំពោះករណីដែលតុលាការបានជួបប្រទះ គឺការស្លាប់របស់ជនជាប់ចោទ អៀង សារី ដែលជាជនជាប់ចោទមួយរូបក្នុងចំណោមជនជាប់ចោទ៤រូបនៅក្នុងសំណុំរឿង០០២ ដោយពុំទាន់ទទួលបានការជំនុំជម្រះចប់សព្វគ្រប់ ដែលជាហេតុធ្វើឲ្យបទចោទប្រកាន់ទាំងអស់ប្រឆាំងនឹង អៀង សារី ត្រូវរលត់ ។[២]

---

[១] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា,"Completion Plan",កែសម្រួលលើកទី៤, ផ្ញើនៅថ្ងៃទី៣១ខែមីនាឆ្នាំ២០១៥ ។

[២] មាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧របស់ព្រះរាជាណាចក្រកម្ពុជា បានចែងថា ការចោទប្រកាន់ព្រហ្មទណ្ឌនឹងត្រូវបញ្ចប់នៅក្នុងករណីដែលជនជាប់ចោទទទួលមរណភាព ។ សូម្បីតែដំណើរការនីតិវិធីបណ្តឹងរដ្ឋប្បវេណីដើម្បីទាមទារសំណងពីជនជាប់ចោទពីសំណាក់ជនរងគ្រោះក៏ត្រូវបានបញ្ចប់ដូចគ្នាដែរ ។

រីឯ ជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវបានអង្គជំនុំជម្រះសាលាដំបូងបំបែកចេញពីសំណុំរឿង០០២ និង ដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌ បន្ទាប់ពីរកឃើញថាមានសម្បទាពុំគ្រប់គ្រាន់ក្នុងការចូលរួមដំណើរការនីតិវិធីតុលាការ ។ ពោលគឺ ជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវបានអ្នកជំនាញរកឃើញថាមានបញ្ហាវង្វេងវង្វាន់ផ្នែកស្មារតី ។

ការស្លាប់របស់ជនជាប់ចោទ អៀង សារី និងបញ្ហាវង្វេងវង្វាន់ស្មារតីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ បានក្លាយជាសញ្ញាអាសន្នមួយក្រើនរំឭកដល់អង្គជំនុំជម្រះឲ្យចាត់វិធានការបន្ទាន់ដើម្បីស្វែងរកមធ្យោបាយពន្លឿនកិច្ចដំណើរការនីតិវិធីជំនុំជម្រះលើជនជាប់ចោទដែលនៅសេសសល់ក្នុងសំណុំរឿង ០០២ ដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ។

ទោះបីជាជនជាប់ចោទ នួន ជា និងជនជាប់ចោទ ខៀវ សំផន នៅមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការនាពេលបច្ចុប្បន្ននេះយ៉ាងណាក្ដី ប៉ុន្តែនៅក្នុងរបាយការណ៍ និងសក្ខីកម្មរបស់អ្នកជំនាញវេជ្ជសាស្ត្របានសង្កត់ធ្ងន់អំពីវ័យចាស់ជរា និងភាពទ្រុឌទ្រោមផ្នែករាងកាយរបស់ជនជាប់ចោទ ។ នៅក្នុងរបាយការណ៍នោះអ្នកជំនាញវេជ្ជសាស្ត្របានកត់សម្គាល់ថា ជនជាប់ចោទ នួន ជា ត្រូវទទួលការព្យាបាលចំពោះជំងឺគាំងបេះដូង ទោះបីជាជំងឺសរសៃរបេះដូងរបស់គាត់នាពេលបច្ចុប្បន្នមានលំនឹង និងត្រូវបានពិនិត្យត្រឹមត្រូវតាមផ្នែកវេជ្ជសាស្ត្រហើយក៏ដោយ ។

សាស្ត្រាចារ្យ ចន ខាំប៊ែល (John CAMPBELL) អ្នកជំនាញជំងឺមនុស្សចាស់ដែលត្រូវបានអង្គជំនុំជម្រះតែងតាំង បានផ្ដល់សក្ខីកម្មកាលខែមីនា ឆ្នាំ២០១៣ ថា "*យើងអាចស្មានពីស្ថានភាពរោគរបស់ជនជាប់ចោទបានតិចតួច ហើយយោងទៅលើអាយុ និងស្ថានភាពជំងឺរ៉ាំរ៉ៃមួយចំនួនរបស់ជនជាប់ចោទ វានឹងមិនមែនជាការភ្ញាក់ផ្អើលឡើយ ប្រសិនបើជនជាប់ចោទពុំអាចរស់នៅតទៀតក្នុងរយៈពេល៦ខែ ខាងមុខនោះ*" ។ ជំងឺសរសៃបេះដូង ជំងឺសរសៃឈាមខួរក្បាល និងភាពទ្រុឌទ្រោមនៃផ្នែករាងកាយរបស់ជនជាប់ចោទ បានធ្វើឲ្យការប៉ាន់ស្មានអំពីស្ថានភាពជំងឺរបស់ជនជាប់ចោទនៅពេលអនាគតមានលក្ខណៈលំបាក និងមានភាពពុំច្បាស់លាស់ ។ សព្វថ្ងៃ ទោះបីជាជនជាប់ចោទ នួន ជា នៅតែអាចបន្តចូលរួមនីតិវិធីសវនាការនៅក្នុងសំណុំរឿង០០២ ដំណាក់កាលទី២ ក៏ដោយ ក៏ការចូលរួមនេះត្រូវធ្វើឡើងពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ ដោយសារតែជនជាប់ចោទរូបនេះមិនអង្គុយស្ដាប់ការជំនុំជម្រះក្ដីមកលើរូបខ្លួនក្នុងបន្ទប់សវនាការក្នុងរយៈពេលយូរបាន ។

ដោយឡែក ជនជាប់ចោទ ខៀវ សំផន ដែលមានអាយុ៨៣ឆ្នាំ ធ្លាប់ទទួលរងជំងឺដាច់សរសៃឈាមខួរក្បាលកាលពីចុងឆ្នាំ២០០៧ ដែលតម្រូវឲ្យមានការព្យាបាលអស់រយៈពេលជាច្រើនខែដើម្បីឲ្យស្ថានភាពជំងឺរបស់គាត់ជាសះស្បើយ ។

ជនជាប់ចោទទាំងពីររូបបានចូលសម្រាកនៅក្នុងមន្ទីរពេទ្យអស់រយៈពេលខុសៗគ្នាក្នុងអំឡុងពេលសវនាការ ។ កាលពីខែមករា ឆ្នាំ២០១៣ ជនជាប់ចោទ នួន ជា ត្រូវបានបញ្ជូនទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យ ដោយសារជំងឺរលាកទងសួតកម្រិតធ្ងន់ ។ បន្ទាប់មកនៅអំឡុងខែកុម្ភៈ ឆ្នាំ២០១៣ ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យម្តងទៀត ដោយសារបញ្ហាសម្ពាធឈាមទាប ។ ចំណែកឯ ជនជាប់ចោទ ខៀវ សំផន ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យដើម្បីទទួលការព្យាបាលកាលពីដើមខែមករា ឆ្នាំ២០១៣ ដោយសារជំងឺរលាកបំពង់កកម្រិតធ្ងន់ ។

ជាការពិត បញ្ហាសុខភាព និងវ័យចាស់ជរារបស់ជនជាប់ចោទពិតជាបានទាញពន្យឺតកិច្ចដំណើរការនីតិវិធីមិនឲ្យសម្រេចលឿនដូចការគ្រោងទុករបស់អង្គជំនុំជម្រះ ហើយទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមផ្តន្ទាទោសជនជាប់ចោទ នួន ជា និង ខៀវ សំផន ដាក់ពន្ធនាគារអស់មួយជីវិតហើយយ៉ាងណាក៏ដោយ ប៉ុន្តែជនជាប់ចោទទាំងពីររូបនៅតែត្រូវបានចាត់ទុកថាជាជនគ្មានទោសនៅឡើយ ដរាបណាពុំទាន់មានសេចក្តីសម្រេចចុងក្រោយពីសំណាក់អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានបាត់លទ្ធភាពក្នុងការចេញសាលក្រមទាក់ទងនឹងជនជាប់ចោទ អៀង សារី និងជនជាប់ចោទ អៀង ធីរិទ្ធ រួចទៅហើយ ។ ដូច្នេះ ប្រសិនបើកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខរបស់ភាគីទាំងអស់ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៅលើកនេះត្រូវអូសបន្លាយ ឬចំណាយពេលយូរ ហើយលទ្ធផលចុងក្រោយបែរជាពុំអាចសម្រេចបានសាលដីកាស្ថាពរដោយសារមរណភាពរបស់ជនជាប់ចោទនោះ នឹងនាំឲ្យមានការខកចិត្តពីសំណាក់ជនរងគ្រោះនៃរបបខ្មែរក្រហមដែលបានទន្ទឹងរង់ចាំយុត្តិធម៌អស់រយៈពេលជាងបីទសវត្សរ៍ ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលចាំបាច់ត្រូវព្យាយាមប្រឹងប្រែងពន្លឿនកិច្ចដំណើរការសវនាការលើបណ្តឹងសាទុក្ខ និងការពិចារណាក្នុងការចេញសេចក្តីសម្រេចឲ្យបានឆាប់រហ័ស នៅមុនពេលជនជាប់ចោទទទួលមរណភាព និងដើម្បីឲ្យជនរងគ្រោះបានឃើញនូវយុត្តិធម៌ពិតប្រាកដសម្រាប់ជីវិតចុងក្រោយ ដែលដកជាប់ស្លាកស្នាមបន្សល់ទុកពីរបបខ្មែរក្រហម ។